# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១២-៤-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៤១១/៣៦៤ ស្ដីពី ការតែងតាំង ឯកឧត្តម លី ស៊ុនហួ ជាទីប្រឹក្សាសម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ៣៧២៩


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១០-៥-២០១១ -អនុក្រឹត្យលេខ ៧៨ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៣៧៣០

០៤-៥-២០១១ -អនុក្រឹត្យលេខ ៥០៩ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៧៣២

០៤-៥-២០១១ -អនុក្រឹត្យលេខ ៥១០ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៣៧៣៣

០៤-៥-២០១១ -អនុក្រឹត្យលេខ ៥១១ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៣៧៣៥

០៤-៥-២០១១ -អនុក្រឹត្យលេខ ៥១២ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣៧៣៦

០៤-៥-២០១១ -អនុក្រឹត្យលេខ ៥១៣ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៧៣៨

០៤-៥-២០១១ -អនុក្រឹត្យលេខ ៥១៤ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ច និង តែងតាំងមុខតំណែងមន្ត្រីរាជការ ៣៧៤០

០៤-៥-២០១១ -អនុក្រឹត្យលេខ ៥១៥ អនក្រ.តត ស្ដីពី ការកែសម្រួលចំនួនគណៈអភិបាលខេត្ត ៣៧៤២

០៤-៥-២០១១ -អនុក្រឹត្យលេខ ៥១៦ អនក្រ.តត ស្ដីពី ការ ជូនមេដាយសហមេត្រី ៣៧៤៤

០៥-៥-២០១១ -អនុក្រឹត្យលេខ ៥១៧ អនក្រ.តត ស្ដីពី ការ តម្លើងឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ ៣៧៤៥

០៥-៥-២០១១ -អនុក្រឹត្យលេខ ៥១៨ អនក្រ.តត ស្ដីពី ការ តម្លើងឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ ៣៧៤៦


### ២~សេចក្ដីសម្រេច


០៥-៥-២០១១ -សេចក្ដីសម្រេចលេខ ២៧ សសរ ស្ដីពី ការបង្កើតគណៈកម្មការចម្រុះរៀបចំពិធីបុណ្យរំលឹកខួប ២៦០០ ឆ្នាំ នៃការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ (វិសាខបូជា) ៣៧៤៧

០៦-៥-២០១១ -សេចក្ដីសម្រេចលេខ ២៨ សសរ ស្ដីពី ការផ្ទេរសិទ្ធការងាររបស់រាជរដ្ឋាភិបាល ៣៧៥០

## III_ការងារបណ្ដាក្រសួង

### ១_ ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៨-៤-២០១១ -ប្រកាសលេខ ៣៦៥ សហវ.ប្រក ស្ដីពី ការបង្កើតបន្ថែមចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាថ្នាក់ជាតិ ៣៧៥១

២៨-៤-២០១១ -ប្រកាសលេខ ៣៦៦ សហវ.ប្រក ស្ដីពី ការបំពេញបន្ថែមគណនី នៃប្លង់គណនេយ្យទូទៅរបស់រដ្ឋ ៣៧៥៣

### ២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៣-៧-២០១០ -លិខិតបញ្ជាក់លេខ ៣២០៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិលអិម ហៅវីឆេច គ្រេឌីង** ៣៧៥៧

១៣-៧-២០១០ -លិខិតបញ្ជាក់លេខ ៣២១២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផេស៊ីហ្វិក ខារហ្គោ (ខេមបូឌា)** ៣៧៥៩

១៣-៧-២០១០ -លិខិតបញ្ជាក់លេខ ៣២១៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូគ ជូ** ៣៧៦១

១៣-៧-២០១០ -លិខិតបញ្ជាក់លេខ ៣២១៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេម-ធីគ ហ្វីសេរ៉ូ & ផ្លេនថេសិន** ៣៧៦៣

១៣-៧-២០១០ -លិខិតបញ្ជាក់លេខ ៣២១៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អានសេនប៊ីយ៉ន (ខេមបូឌា) អ៊ិនវេសមេន ខនសាល់ធីង** ៣៧៦៥

# ព្រះរាជក្រឹត្យ

នស/រកត/០៤១១/៣៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **លី ស៊ុងហួ** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៤.៣៦៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១១

លេខៈ ៣៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ៧៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ , ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៧០ អនក្រ.បក, ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១** : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៥.០០០ លានរៀល (ប្រាំពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាខាងក្រៅ) ជូនក្រសួងអភិវឌ្ឍន៍ជនបទ សំរាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

**មាត្រា២**: ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ចំណាយថែទាំផ្លូវជាលក្ខណៈខួបក្រាលគ្រួសក្រហម ៥ ខ្សែ ប្រវែងសរុប ៣៧.៩៧០ ម៉ែត្រ កែលម្អផ្លូវពីក្រាលគ្រួសក្រហម ទៅជាផ្លូវកៅស៊ូប្រភេទ DBST ប្រវែង ២.៤០០ ម៉ែត្រ រៀបចំការពារជើងទេរប្រឡាយ ប្រវែង ៩១២ ម៉ែត្រ និង សាងសង់លូរំដោះទឹកគ្រប់ប្រភេទ ចំនួន ៥ កន្លែងនៅស្រុកពញាក្រែក ខេត្តកំពង់ចាម ។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៥០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ជូនឧកញ៉ា **គាំង ម៉េងហ៊ុយ** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងឧបដ្ឋានសាលា ជងទង់ របងវត្ត សាលាទទួលភ្ញៀវ ចាក់ដីបំពេញ ទីធ្លាវត្ត និងសមិទ្ធផលផ្សេងៗទៀត នៅវត្តជោត្តនារាម (ទឹកល្អក់) ឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចំណាយថវិកាចំនួន ១៣២.៧៣៥ ដុល្លារអាមេរិក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួលៈ**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៦០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន១៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងឧបដ្ឋានសាលា ដងទង់ របងវត្ត សាលាទទួលភ្ញៀវ ចាក់ដីបំពេញទីធ្លាវត្ត និងសមិទ្ធផលផ្សេងៗទៀត នៅវត្តជោត្តនារាម (ទឹកល្អក់) ឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដូចមានរាយព្រនាមនិងនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ:**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **សាន** | **គីន** | ចៅអធិការវត្តជោត្តនារាម | បច្ច័យចំនួន១០.០០០ ដុល្លារ |
| ២-ឧកញ៉ា | **តាំង** | **ផេងឆោ** | សប្បុរសជនរាជធានីភ្នំពេញ | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៣-លោក | **កែ** | **សុខុម** | សប្បុរសជននៅខេត្តកំពង់ស្ពឺ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤-លោក | **យស់** | **សាមុត** | សប្បុរសជននៅខេត្តកំពង់ស្ពឺ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៥-អ្នកស្រី | **ម៉ូ** | **សៀកហ៊ុន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៦-លោក | **ទូ** | **ឆេងអ៊ួ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ២១.០០០ ដុល្លារ |
| ៧-លោក | **អ៊ឹង** | **ហាំងឆាយ** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ៨-ក្រុមហ៊ុនតៃវ៉ាន់ | | | នៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៩-លោក | **រស់** | **រាសី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ១០-អ្នកស្រី | **ឥន្ទ** | **ឱុទ្ធី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ:**

| | | | | |
|---|---|---|---|---|
| ១-លោក | **ខូច** | **ម៉េងហ៊ាង** | សប្បុរសជននៅអូស្ត្រាលី | ថវិកាចំនួន ៣.៥០០ ដុល្លារ |
| ២-លោក | **អាង** | **សំបុណ្យ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៤.០០០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ៣-លោក | ហ៊ាង គង់ | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៣.៦០០ ដុល្លារ |
| ៤-លោក | ស៊ូ ឈរុន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៣.៥០០ ដុល្លារ |
| ៥-លោក | ឃឹម គួច | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន | ៣.០០០ ដុល្លារ |
| ៦-លោក | ចាន តួនី | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ២.៥០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៥១១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាង អភិវឌ្ឍន៍មូលដ្ឋាន នៅតាមបណ្តាឃុំនានា ស្ថិតក្នុងស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | លោក | **ចាន់** | **ស៊ីទន** | អនុប្រធានការិយាល័យគណនេយ្យ រតនាគារ ខេត្តកណ្តាល |
| ២- | លោក | **ឆាល់** | **សំអូន** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣- | លោក | **តែ** | **សម្បត្តិ** | សប្បុរសជននៅស្រុកល្វាឯម |
| ៤- | លោក | **ពុំ** | **ឈុន** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៥- | ឧបាសិកា | **ធេព** | **ប៊ុនស្រោល** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៦- | លោក | **អៀ** | **លាងភាវ** | សប្បុរសជននៅក្រុងតាខ្មៅ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥១៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការតាមមូលដ្ឋាន ចំនួន ៣០រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមកសាង អភិវឌ្ឍន៍មូលដ្ឋាន នៅតាមបណ្តាឃុំនានា ស្ថិតក្នុងស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១- | លោក | **ចាប ចំរើន** | នាយកអនុវិទ្យាល័យ កោះរះ |
| ២- | លោក | **អ៊ុំ ប៊ុនថន** | នាយកអនុវិទ្យាល័យ ព្រែកគង់រាជ |
| ៣- | លោក | **ឡឹក ពាន** | នាយកអនុវិទ្យាល័យ ព្រែកឬស្សី |
| ៤- | លោក | **នូ សារុន** | នាយកបឋមសិក្សា ហ៊ុន សែន ខ្មោការ |
| ៥- | លោក | **ម៉ែន យន់** | នាយកបឋមសិក្សា ផ្លូវត្រី |
| ៦- | លោក | **ចាប ប៊ុនថុល** | នាយកបឋមសិក្សា ហ៊ុន សែន បឹងគ្រំ |
| ៧- | លោក | **ហ៊ិល សាគាំ** | នាយកបឋមសិក្សា ព្រែកគង់រាជ |
| ៨- | លោក | **ឯម សំអឿន** | ប្រធានមណ្ឌលសុខភាព អរិយក្សត្រ |
| ៩- | លោកស្រី | **ឡុង យ៉ាវ៉ាន់** | អនុប្រធានមណ្ឌលសុខភាព ពាមឧកញ៉ាអុង |
| ១០- | លោកស្រី | **អ៊ូ តូរី** | បុគ្គលិកមណ្ឌលសុខភាព ពាមឧកញ៉ាអុង |
| ១១- | លោកស្រី | **លី សុពណ៌** | បុគ្គលិកមណ្ឌលសុខភាព ទឹកឃ្លាំង |
| ១២- | លោក | **កើត សុខ** | បុគ្គលិកមណ្ឌលសុខភាព ភូមិធំសុខសប្បាយ |
| ១៣- | លោកស្រី | **សាន មុនិតា** | ប្រធានមណ្ឌលសុខភាព កោះកែវ |

| | | | |
|---|---|---|---|
| ១៤- | លោក | យ៉ា រ៉ាន់ | អនុប្រធានមណ្ឌលសុខភាព កោះកែវ |
| ១៥- | លោកស្រី | ខុម សុទឿន | អនុប្រធានមណ្ឌលសុខភាព ព្រែកឫស្សី |
| ១៦- | លោកស្រី | កែន សុលាន | បុគ្គលិកមណ្ឌលសុខភាព ព្រែកឫស្សី |
| ១៧- | លោកស្រី | ធីម ម៉ុនធី | ប្រធានមណ្ឌលសុខភាព បារ៉ុង |
| ១៨- | លោក | ម៉ន សាធុន | អនុប្រធានមណ្ឌលសុខភាព បារ៉ុង |
| ១៩- | លោក | ម៉េង សាធុន | នាយប៉ុស្តិ៍ នគរបាល សារិកាកែវ |
| ២០- | លោក | យ៉ន ធី | នាយប៉ុស្តិ៍ នគរបាល ព្រែករៃ |
| ២១- | លោក | ស្តើង ចន្ថា | នាយប៉ុស្តិ៍ នគរបាល ព្រែកក្មេង |
| ២២- | លោក | ជឿន សេង | នាយប៉ុស្តិ៍ នគរបាល ព្រែកឫស្សី |
| ២៣- | លោក | អ៊ុង យុទ្ធថា | នាយប៉ុស្តិ៍ នគរបាល ទឹកឃ្លាំង |
| ២៤- | លោក | កេត ណៃ | នាយប៉ុស្តិ៍ នគរបាល ល្វាសរ |
| ២៥- | លោក | ចាន់ សយ | នាយប៉ុស្តិ៍ នគរបាល ភូមិធំ |

ខ-មេជាយប្រាក់ការងារ

| | | | |
|---|---|---|---|
| ១- | លោក | ភោគ សារី | ក្រុមការងារស្រុកល្វាឯម |
| ២- | លោក | ភោគ និត្យ | ក្រុមការងារស្រុកល្វាឯម |
| ៣- | លោកស្រី | ភោគ មុំ | ក្រុមការងារស្រុកល្វាឯម |
| ៤- | លោក | ឈួន សុវណ្ណា | ក្រុមការងារស្រុកល្វាឯម |
| ៥- | លោកស្រី | ប៊ិច យ៉ុន | ក្រុមការងារស្រុកល្វាឯម |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៥១៣ . អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១៤រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមកសាង អភិវឌ្ឍន៍មូលដ្ឋាន នៅតាមបណ្ដាឃុំនានា ស្ថិតក្នុងស្រុកល្វាឯម ខេត្តកណ្ដាល ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

- លោក **រស់ លន់** អនុប្រធានហិរញ្ញវត្ថុមូលដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

១- លោក **ជាក់ ហ៊ុយ** សប្បុរសជននៅ រាជធានីភ្នំពេញ
២- លោក **ចាន់ ទ៉ាត** មន្ត្រីគណៈកម្មាការជាតិ រៀបចំការបោះឆ្នោត
៣- លោក **ឡាង លីមហ៊ាង** សប្បុរសជននៅរាជធានីភ្នំពេញ
៤- លោក **លន់ ខុំ** នាយករដ្ឋបាលសាលាស្រុកល្វាឯម
៥- លោក **ជួន តារាពន្យ** នាយករងរដ្ឋបាលសាលាស្រុកល្វាឯម

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សប្ញទ្ធិ**

១- លោក **ជា ចាន់ហេង** ប្រធានការិយាល័យ វប្បធម៌ និងវិចិត្រសិល្បៈស្រុកល្វាឯម
២- អ្នកស្រី **នៅ ចាន់ថា** សប្បុរសជននៅរាជធានីភ្នំពេញ
៣- លោកយាយ **អ៊ុច សោ** សប្បុរសជននៅរាជធានីភ្នំពេញ
៤- លោក **ឆា ឈុនហុក** សប្បុរសជននៅរាជធានីភ្នំពេញ
៥- លោក **សៀង ខូន** សប្បុរសជននៅស្រុកល្វាឯម

៦- អ្នកស្រី **លីម នឿន** សប្បុរសជននៅរាជធានីភ្នំពេញ
៧- អ្នកស្រី **នៅ ចាន់ធី** សប្បុរសជននៅរាជធានីភ្នំពេញ
៨- អ្នកស្រី **ជឹម ចិន្តា** សប្បុរសជននៅរាជធានីភ្នំពេញ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **ឈឹម ឈន** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ១ ពីអភិបាលរងខេត្តតាកែវ ទៅជាអភិបាលរងខេត្តកំពង់ឆ្នាំង ជំនួសលោក **ហ៊ីង សារិន្ទ** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

**មាត្រា ២ :** ត្រូវបានតែងតាំងមុខតំណែងមន្ត្រីរាជការ ០២រូប ជាអភិបាលរងនៃគណៈអភិបាលខេត្តតាកែវ និងខេត្តស្ទឹងត្រែង ដូចមានរាយនាមខាងក្រោម :

១-លោក **គាន់ ធុរ្សី** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៧ ជាអភិបាលរងខេត្តតាកែវ ជំនួសលោក **ឈឹម ឈន** ។

២-លោក **ជិន សុធា** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ១ ជាអភិបាលរងខេត្តស្ទឹងត្រែង ជំនួសលោក **ភោគ សំអេន** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

**មាត្រា ៣ :** គ្រប់បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលចំនួនគណៈអភិបាលខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានកែសម្រួលចំនួនគណៈអភិបាលខេត្ត ដោយបន្ថែមអភិបាលរងខេត្តមួយនាក់ សម្រាប់ខេត្តចំនួន ១៧ ដែលមានគណៈអភិបាលខេត្ត ០៥នាក់ និង ០៦នាក់ ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ខេត្ត បន្ទាយមានជ័យ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ២- | ខេត្ត កំពង់ស្ពឺ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៣- | ខេត្ត កំពង់ធំ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៤- | ខេត្ត កំពង់ឆ្នាំង | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៥- | ខេត្ត កំពត | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៦- | ខេត្ត ស្វាយរៀង | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៧- | ខេត្តពោធិ៍សាត់ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៨- | ខេត្ត ក្រចេះ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៩- | ខេត្ត ព្រះសីហនុ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ១០- | ខេត្ត ព្រះវិហារ | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១១- | ខេត្ត រតនគិរី | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១២- | ខេត្ត កោះកុង | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១៣- | ខេត្ត ស្ទឹងត្រែង | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១៤- | ខេត្ត ឧត្តរមានជ័យ | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១៥- | ខេត្ត មណ្ឌលគិរី | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១៦- | ខេត្ត កែប | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១៧- | ខេត្ត ប៉ៃលិន | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ ។ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១៦-អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយ សហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានបំពាក់មេដាយ **សហមេត្រី ថ្នាក់ធិបឌិន្ទ** ជូនដល់លោក Gregoire CHASSAING នាយស្នងការសេនានុព័ន្ធប៉ូលីសបារាំង នៃស្ថានទូតបារាំងប្រចាំកម្ពុជា បានជួយឧបត្ថម្ភគាំទ្រក្នុងការផ្លាស់ប្តូរព័ត៌មានសំខាន់ៗជាប្រចាំ និងជួយដល់ការងារបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិកម្ពុជា ។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១៧ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ នាយទាហាន ដែលបានពលីជីវិតយ៉ាងអង់អាចក្លាហាន នៅសមរភូមិទិសប្រាសាទតាក្របី ជូនសព

- អនុសេនីយ៍ឯក **ថោង ខាន** អត្តលេខ ០១០០៨៦ មេបញ្ជាការ អនុសេនាធំលេខ ៣ វរសេនាតូចលេខ ៤២៣ កងពលតូចថ្មើរជើងលេខ ៤២ យោធភូមិភាគទី ៤ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥១៨ អនក្រ.[illegible]

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ នាយទាហាន ដែលបានពលីជីវិតយ៉ាងអង់អាចក្លាហាន នៅសមរភូមិទិសប្រាសាទតាក្របី ជូនសព

- វរសេនីយ៍ត្រី **ឌុល សារ៉ែម** អត្តលេខ ០០៥២២១ នាយសេនាធិការ វរសេនាតូចលេខ ៤២៣ កងពលតូចថ្មើរជើងលេខ ៤២ យោធភូមិភាគទី ៤ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៧៧ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការចម្រុះរៀបចំពិធីបុណ្យរំលឹកខួប ២៦០០ ឆ្នាំ នៃការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ (វិសាខបូជា)

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មការចម្រុះរៀបចំពិធីបុណ្យរំលឹកខួប **២៦០០ឆ្នាំ នៃការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤-១៥កើត និងថ្ងៃ១រោជ ខែពិសាខ ឆ្នាំថោះ ត្រីស័ក ព.ស២៥៥៥ ត្រូវនឹងថ្ងៃទី១៦-១៧-១៨ ខែឧសភា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ** ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១-សម្តេចព្រះមហាសុមេធាធិបតី | **នន្ទ ង៉ែត** | **ព្រះអធិបតី** |
| ២-សម្តេចព្រះពោធិវង្ស | **អ៊ំ លឹមហេង** | ព្រះអធិបតីរង |
| ៣-សម្តេចព្រះវន្ន័រត | **ណយ ច្រឹក** | ព្រះអធិបតីរង |
| ៤-សម្តេចព្រះឧត្តមបញ្ញា | **ដួង ផង់** | ព្រះអធិបតីរង |
| ៥-សម្តេចព្រះឧត្តមវង្សា | **មួង រ៉ា** | ព្រះអធិបតីរង |
| ៦-សម្តេចព្រះឧត្តមចរិយា | **ឈឹង ប៊ុនឈា** | ព្រះអធិបតីរង |
| ៧-សម្តេចព្រះអរិយវង្ស | **សោរ៉ៃ ចន្ទថុល្ល** | ព្រះអធិបតីរង |
| ៨-សម្តេចព្រះឧត្តមមុនី | **យឿង យ៉ាត** | ព្រះអធិបតីរង |
| ៩-ព្រះពុទ្ធវង្ស | **ជា សំអាង** | ព្រះអធិបតីរង |
| ១០-ព្រះពុទ្ធាចារ្យ | **ឱុច សុខទោហា** | ព្រះអធិបតីរង |
| ១១-ព្រះមហារាជធម្ម | **វង្ស អានេតា** | ព្រះអធិបតីរង |
| ១២-ឯកឧត្តម | **មិន ឃិន** | ប្រធាន |
| ១៣-ឯកឧត្តម | **ខៀវ កាញារីទ្ធ** | អនុប្រធាន |

| | | |
|---|---|---|
| ១៤-ឯកឧត្តម | ហ៊ឹម ន័ម | អនុប្រធាន |
| ១៥-ឯកឧត្តម | អ៊ុក រ៉ាប៊ុន | អនុប្រធាន |
| ១៦-ឯកឧត្តម | កែប ជុតិមា | អនុប្រធាន |
| ១៧-ឯកឧត្តម | ប៉ែន ស៊ីម៉ន | អនុប្រធាន |
| ១៨-ឯកឧត្តមឧកញ៉ា | ពុង ឃាវសែ | អនុប្រធាន |
| ១៩-ឯកឧត្តម | ស៊ឹម វណ្ណា | សមាជិក |
| ២០-ឯកឧត្តម | ជា គាន | សមាជិក |
| ២១-ឯកឧត្តម | ផ្លោក ផន | សមាជិក |
| ២២-ឯកឧត្តម | ម៉ៅ អាយុទ្ធ | សមាជិក |
| ២៣-ឯកឧត្តម | ឃឹម សារិទ្ធ | សមាជិក |
| ២៤-ឯកឧត្តម នាយឧត្តមសេនីយ៍ | នេត សាវឿន | សមាជិក |
| ២៥-ឯកឧត្តម នាយឧត្តមសេនីយ៍ | សៅ សុខា | សមាជិក |
| ២៦-ឯកឧត្តម | ប៊ុន សម | សមាជិក |
| ២៧-ឯកឧត្តម | យូ ស៊ុនឡុង | សមាជិក |
| ២៨-ឯកឧត្តម | ប៊ួន លីមហេង | សមាជិក |
| ២៩-ឯកឧត្តម | នី សុគន្ធ | សមាជិក |
| ៣០-ឯកឧត្តម | ញ៉ែម វ៉ាលី | សមាជិក |
| ៣១-ឯកឧត្តម | សេង សុមុនី | សមាជិក |
| ៣២-ឯកឧត្តម | គីម គុណវឌ្ឍនី | សមាជិក |
| ៣៣-ឯកឧត្តម | គង់ យ៉ាន | សមាជិក |
| ៣៤-ឯកឧត្តម | ទួន ទុន្នី | សមាជិក |
| ៣៥-លោក | អ៊ាត សីលា | សមាជិក |
| ៣៦-លោក | សាន សម្ផស្ស | សមាជិក |
| ៣៧-ឧកញ៉ាមហាឧបាសិកា | សុខ អ៊ឹម | សមាជិក |
| ៣៨-លោក | ហេង មុនីចិន្តា | សមាជិក |
| ៣៩-គ្រប់ក្រសួង-ស្ថាប័ន | | សមាជិក |
| ៤០-ឯកឧត្តមអភិបាល ប្រធានក្រុមប្រឹក្សា គ្រប់រាជធានី-ខេត្ត | | សមាជិក |
| ៤១-មន្ទីរធម្មការ និងសាសនា ព្រះមេគណទាំងពីរគណៈ គ្រប់ខេត្ត -រាជធានី | | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះ មានមុខងារ និងភារកិច្ចដូចតទៅ :

- គ្រប់វត្តអារាម ត្រូវបំផុសបំបួសកុលបុត្រ-កុលធីតាជាភិក្ខុ ឬសាមណេរឱ្យបាន **១០**រូបយ៉ាងតិច និងមានប្រារព្ធពិធី នមស្សការ សមាទានសីល ចម្រើនព្រះបរិត្ត សូត្រធម៌បទប្រកាសរំលឹកខួប **២៦០០** នៃការត្រាស់ដឹងរបស់ **ព្រះសម្មាសម្ពុទ្ធ** បទសារភញ្ញ និងសម្តែងធម៌ទេសនា ដោយបញ្ជ្រាបការអប់រំឱ្យស្គាល់បុណ្យបាប គុណទោស សំដៅអប់រំចរិយាធម៌ សុជីវធម៌ គុណធម៌ តាមមាគ៌ា ព្រះពុទ្ធសាសនា និងបញ្ជ្រាបការអប់រំអំពី ការគោរពសិទ្ធិនារី គោរពច្បាប់ចរាចរ កុំឱ្យប្រព្រឹត្តអំពើហិង្សា សេពគ្រឿងញៀន អំពើជួញដូរមនុស្សជាដើម ។

- រៀបចំទីតាំងស្តង់ រោងទិស នៅកន្លែងប្រារព្ធពិធី (**មជ្ឈមណ្ឌលកោះពេជ្រ**) បែងចែកជូនសាលារាជធានីភ្នំពេញ និងគ្រប់បណ្តាខេត្ត សម្រាប់ទទួលព្រះសង្ឃ និងពុទ្ធបរិស័ទមកពីខេត្តសាមីចូលរួមតាម ចំនួនកំណត់។ ស្តង់នីមួយៗ ត្រូវតុបតែងលម្អក្បូរក្បាច់រចនា ភ្ជាប់ទៅនឹងខ្លឹមសារនៃពិធីបុណ្យរំលឹកខួប **២៦០០ឆ្នាំ** នៃការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ តាមទំនងពុទ្ធប្រវត្តិ **រៀបចំពិពណ៌ព្រះពុទ្ធសាសនា**។
- រៀបចំពិធីបួងសួងម្ចាស់ទឹកម្ចាស់ដីសុំសុខសប្បាយប្រសិទ្ធពរជ័យជូនចំពោះថ្នាក់ដឹកនាំកំពូលរបស់ជាតិ និងប្រជារាស្ត្រ
- រៀបចំពិធីរាប់បាត្រប្រគេនព្រះសង្ឃ ចំនួន **២៦០០** ព្រះអង្គ ឧទ្ទិសដល់ខួប **២៦០០ឆ្នាំ** នៃការត្រាស់ដឹងរបស់ ព្រះសម្មាសម្ពុទ្ធ និងឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារី ប្រជាជនកម្ពុជា ជាពិសេសវិញ្ញាណក្ខន្ធវីរៈ យុទ្ធជន ពលីបុព្វហេតុការពារព្រំដែនប្រាសាទព្រះវិហារកន្លងមក និងជូនចំពោះកងកំលាំងប្រដាប់អាវុធការពារព្រំដែនប្រាសាទព្រះវិហារឱ្យទទួលបានជោគជ័យ
- សហការជាមួយក្រសួង ស្ថាប័ន រាជធានីខេត្តពាក់ព័ន្ធ និងគណសង្ឃនាយក ដើម្បីរៀបចំពិធីខាងលើនេះ ឱ្យបានជោគជ័យ
- ត្រួតពិនិត្យ និងលើកសំណើដោះស្រាយរាល់បញ្ហានានា ការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងពិធីបុណ្យឱ្យបានល្អប្រសើរ
- លើកគម្រោងចំណូលចំណាយ អំពាវនាវសប្បុរសជន ក្នុងនិងក្រៅប្រទេស ជួយឧបត្ថម្ភដើម្បីបំរើឱ្យពិធីបុណ្យ
- បំពេញភារកិច្ចជាក់ស្តែងផ្សេងទៀត តាមការចាំបាច់សម្រាប់បំរើឱ្យពិធីបុណ្យទាំងមូល
- ត្រៀមលក្ខណៈផ្សព្វផ្សាយឱ្យបានទូលំទូលាយ តាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព ទាំងក្នុងនិងក្រៅប្រទេស ដោយមានបដារពាក្យស្លោកតូចធំ នៅតាមទីប្រជុំជន រាជធានី-ខេត្ត ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា តាមទូរទស្សន៍ តាមសារព័ត៌មាន ។ល។ ដោយដាក់រូបភាពពុទ្ធប្រវត្តិ។

**ប្រការ ៣ :** គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការ និងក្រុមការងារជំនាញបន្ថែមទៀតជាជំនួយការតាមតម្រូវការចាំបាច់។

**ប្រការ ៤ :** សមាសភាពគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិពេញលេញក្នុងការដឹកនាំការងារ តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ សាលារាជធានី-គ្រប់ខេត្ត សម្តេច ព្រះរាជាគណៈ ព្រះមេគណទាំងពីគណៈ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>ចម្លងជូន</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១ និងប្រការ ៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៖ ២៧៤. សសរ

# សេចក្តីសម្រេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### ស ម្រេ ច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញទៅចូលរួម**កិច្ចប្រជុំកំពូលអាស៊ាន លើកទី ១៨** នៅទីក្រុងហ្សាកាតា. សាធារណរដ្ឋឥណ្ឌូនេស៊ី ចាប់ពីថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១១ រហូតដល់ពេលសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងឯកឧត្តម **ស ខេង** ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៦៥.....សហវ.ប្រក

រាជធានីភ្នំពេញ . ថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០១១

## ប្រកាស
## ស្តីពីការបង្កើតបន្ថែមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាថ្នាក់ជាតិ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ . ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ . ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧. ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក.ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក.ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ស្តីពីការតំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**ប្រការ១:** ត្រូវបានដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចបន្ថែមនៃមាតិកាថវិកាថ្នាក់ជាតិដូចខាងក្រោម :

ផ្នែកចំណូល:

-អនុគណនី ៧០២៧ អាករលើតម្លៃបន្ថែមរបបនាំចូលទំនិញ និង សម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ )

-អនុគណនី ៧១០៧ ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ )

ផ្នែកចំណាយ :

-គណនី ៦៣៥ បន្ទុកពន្ធគយលើការនាំចូលទំនិញ និង សម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ )

-គណនី ៦៣៦ បន្ទុកពន្ធគយលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ )

**ប្រការ២:** ចំណាត់សេដ្ឋកិច្ចនៃមាតិកាថវិកាដូចចែងក្នុងប្រការ១ ខាងលើ ត្រូវបានបំពេញបន្ថែមលើប្រកាសលេខ ១៤៤៨ សហវ.ប្រក. ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។

**ប្រការ៣:** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី

( ដើម្បីជ្រាបជាព័ត៌មាន )

-រាជកិច្ច

( ដើម្បីផ្សព្វផ្សាយ )

- អគ្គនាយកដ្ឋានរតនាគារជាតិ

" ដើម្បីអនុវត្ត "

- ឯកសារ_កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ : ៣២៦....សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១១

# ប្រកាស
## ស្តីពី
## ការបំពេញបន្ថែមគណនី នៃប្លង់គណនេយ្យទូទៅរបស់រដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយអនុវត្តនីតិវិធីចំណាត់ថ្នាក់ [illegible] នៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម /១២១០/០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតំឡើងទីចាត់ការគណនេយ្យ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥.២៣.៧២៤ ៦៦៤ ទូរសារ : ៨៥៥.២៣.៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com

សាធារណៈ

- បានឃើញអនុក្រឹត្យលេខ ០៤ អ.ន.ក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៤៩១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅរបស់រដ្ឋ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## សម្រេច

**ប្រការ ១:** ត្រូវបានបំពេញបន្ថែមគណនី និងអនុគណនីនៅក្នុងប្លង់គណនេយ្យទូទៅរបស់រដ្ឋ ដែលមានឈ្មោះ និង លេខសម្គាល់ ដូចខាងក្រោម :

- បង្កើតគណនីចំណាយថវិកា " បន្ទុកពន្ធគយលើការនាំចូលទំនិញ និង សម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៦៣៥ ស្ថិតក្នុងជំពូក "ពន្ធ និង អាករ" មានលេខសម្គាល់ ៦៣ ។
- បង្កើតគណនីចំណាយថវិកា " បន្ទុកពន្ធគយលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៦៣៦ ស្ថិតក្នុងជំពូក " ពន្ធ និង អាករ" មានលេខសម្គាល់ ៦៣ ។
- បង្កើតអនុគណនីចំណូលថវិកា "អាករលើតម្លៃបន្ថែមរបបនាំចូលទំនិញ និងសម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ) " មានលេខសម្គាល់ ៧០២៧ ស្ថិតក្នុងគណនី " ពន្ធទូទៅលើទ្រព្យសម្បត្តិ និងសេវា " មានលេខសម្គាល់ ៧០២ ។
- បង្កើតអនុគណនីចំណូលថវិកា" ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៧១០៧ ស្ថិតក្នុងគណនី "ពន្ធគយលើការនាំចូល " មានលេខសម្គាល់ ៧១០ ។

**ប្រការ ២: ប្រព្រឹត្តិកម្ម នៃគណនី និង អនុគណនី :**

គណនី និង អនុគណនី ដែលបានបំពេញបន្ថែមដូចប្រការ ១ មានប្រព្រឹត្តិកម្មដូចខាងក្រោម ៖

**- គណនី " ពន្ធគយលើការនាំចូលទំនិញ និង សម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ )" មានលេខសម្គាល់ ៦៣៥ :**

គណនីលេខ ៦៣៥ បើកនៅអគ្គនាយកដ្ឋានរតនាគារជាតិ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ពន្ធនាំចូល និងសម្ភារៈកសិកម្មដែលជាបន្ទុករបស់រដ្ឋ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់នាំចូលទំនិញ និងសម្ភារៈកសិកម្ម ដែលជាបន្ទុករបស់រដ្ឋ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើនាំពន្ធចូលទំនិញ និង សម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទានិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាលើពន្ធនាំចូលទំនិញ និងសម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**- គណនី " ពន្ធគយលើការនាំចូលទំនិញ ជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៦៣៦ :**

គណនីលេខ ៦៣៦ បើកនៅអគ្គនាយកដ្ឋានរតនាគារជាតិ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថដែលជាបន្ទុករបស់រដ្ឋ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ )

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ) ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទានិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាលើពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ ) ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**- អនុគណនីចំណូលថវិកា " អាករលើតម្លៃបន្ថែមរបបនាំចូលទំនិញ និង សម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៧០២៧ :**

អនុគណនីលេខ ៧០២៧ បើកនៅអគ្គនាយកដ្ឋានរតនាគារជាតិ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់អាករលើតម្លៃបន្ថែមលើការនាំចូលទំនិញ និងសម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) ។ ការកត់ត្រាជាចំណូលថវិកាក្នុងគណនីលេខ ៧០២៧ ដើម្បីមានតុល្យភាពរវាងចំណាយថវិកា ( បន្ទុករបស់រដ្ឋ ) ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាជាចំណូលថវិកានូវទឹកប្រាក់អាករលើតម្លៃបន្ថែមលើការនាំចូលទំនិញនិង សម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាជាចំណូលថវិកានូវទឹកប្រាក់អាករលើតម្លៃបន្ថែមលើការនាំចូលទំនិញ និងសម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ )

សមតុល្យ : ឥណទានិក បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកានូវអាករលើតម្លៃបន្ថែមលើការនាំចូលទំនិញ និងសម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**- អនុគណនីចំណូលថវិកា " ពន្ធគយលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៧១០៧ :**

អនុគណនីលេខ ៧១០៧ បើកនៅអគ្គនាយកដ្ឋានរតនាគារជាតិ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់

ចាត់ទុកជាចំណូលថវិកានូវទឹកប្រាក់ដែលបានកត់ត្រាជាចំណាយថវិកាជាបន្ទុករបស់រដ្ឋលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ។ ការកត់ត្រាជាចំណូលថវិកាក្នុងគណនីលេខ ៧១០៧ ដើម្បីមានតុល្យភាពរវាងចំណាយថវិកាជាបន្ទុករបស់រដ្ឋ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាជាចំណូលថវិកានូវទឹកប្រាក់ពន្ធគយលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាជាចំណូលថវិកានូវទឹកប្រាក់ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ)

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកានូវទឹកប្រាក់ពន្ធនាំចូលទំនិជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ ) ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ប្រការ ៣:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤:** ប្រកាសនេះចូលជាធរមានចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

<u>**ចំលងជូន**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត-ក្រុង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣/៧០៧ ពណ.ចបព

ភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **អិលអឹម ហេរីធេច ត្រេឌីង**
**LM Heritage Trading Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៣៨១KH/២០១០ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **អ៊ុំ លក្ខិណា** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **ម៉ៅ សយ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៨១ ផ្លូវលេខ ១៦៣ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានភារកិច្ចមកដាក់ល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានការ របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខ ជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**កឹម_ស៊ីថន**

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ [illegible] ពណ.ចបព

ភ្នំពេញថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
### សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **ផៅស៊ីហ្វិក ខាហ្គោ (ខេមបូឌា)**
**PACIFIC CARGO (CAMBODIA) Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៣៣៦KH/២០១០ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **អុឹ មល្លីកា** ប្រធានក្រុមប្រឹក្សាភិបាល
លោក **គីក ពន្លក** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៣២ J មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហារ័ណ អាហារ័ណទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្ដូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកគាំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខ ជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

កឹម_ស៊ីថន

**<u>ចម្លងជូន</u>**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ក្រសួងបរិស្ថាន
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ក្រសួងទេសចរណ៍
ក្រសួងសុខាភិបាល
ធនាគារជាតិនៃកម្ពុជា
ក្រសួងពត៌មាន
ក្រសួងអប់រំ យុវជន និងកីឡា
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
ក្រសួងសាធារណការ និងដឹកជញ្ជូន
រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
សាលារាជធានីភ្នំពេញ
មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
ស.ស.រ ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៧១៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **ហ្គូត ដូ**
GOUTTE D'EAU Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៣៨៧KH/២០១០ ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១០
មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :
លោកស្រី LEU VERONIKA RUTH ប្រធានក្រុមប្រឹក្សាភិបាល
លោក MOLINARI FABIC MICHELE អភិបាល
លោក JAKOB CHRISTOPH អភិបាល
លោកស្រី **ឆ្លូប៊ីហ្គី ចន្ថា** អភិបាល
លោក **សំ សុវណ្ណារិទ្ធ** អភិបាល
លោក **ស្រី សុគន្ធ** អភិបាល
លោក **ឡុង សានរិទ្ធី** អភិបាល
លោក **យ៉េម ហ៊្សិច** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ៤.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៨ ផ្លូវលេខ ១៣៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្មៈទិញ លក់ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការដឹកជញ្ជូនដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈទំនិញ គ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់ផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន :ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**គីម_ស៊ីថន**

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ក.ស.ន - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៧២១៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន FREELAND UNIVERSAL LIMITED (BVI) ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេម - ធីក ហ្វរីសទ្រី & ផ្លេនថេសិន**
**CAM - TIG FORESTRY & PLANTATION Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៣៥៧E/២០១០ ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក TSENG, CHING-CHEN "តតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក LEE, MON-LUN "តតិយជន" អភិបាល
លោក CHEN, WANG-CHI "តតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១២៨ G ១០ វិថីសម្ដេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហារ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្ដូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងវេចខ្ចប់ទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាលដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**ស៊ីថន**

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.ៈ - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣២៧៥ ពណ.ចបព

ភ្នំពេញថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **អានសេនប៊ីយ៉ន (ខេមបូឌា) អ៊ិនវេសមេន ខនសាល់ធីង**
**ANSENBEYOND (CAMBODIA) INVESTMENT CONSULTING Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៣៦២E/២០១០ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១០

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក ZHENG YANG ប្រធានក្រុមប្រឹក្សាភិបាល
លោក **តាំង ហួត** អភិបាល
លោកស្រី LAM JING JING អភិបាល

៣- ដើមទុនក្រុមហ៊ុន : ១២.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៥៧ Eo ផ្លូវលេខ ១០៥ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងថែរក្សាទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម...

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកលប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខ ជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ផ្ញើរមើលបិការ

**ចាម ប្រសិទ្ធ** 

**គឹម ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

រ.ស.រ.- ឯកសារ - កាលប្បវត្តិ